01036445

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

**ឯកសារលេខ/No: D205/1/1/2**

***ក្នុងនាមប្រជាជនខ្មែរ និងក្នុងនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ***

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០៤/០៧-០៩-២០០៩-អវតក/កសចស (អបជ ១១)

ចំពោះមុខ: **ចៅក្រម ប្រាក់ គឹមសាន** **ប្រធាន**
**ចៅក្រម** Rowan DOWNING
**ចៅក្រម ន៉ីយ ថុល**
**ចៅក្រម** Chang-Ho CHUNG
**ចៅក្រម ហួត វុទ្ធី**

កាលបរិច្ឆេទ: ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០១៤

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 13 / 11 / 2014
ម៉ោង (Time/Heure): 10:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Uch Arun

**សាធារណៈ: (សំណៅកោសលុប)**

**សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងដីកាសម្រេចបដិសេធសំណើរបស់គាត់សុំការបំភ្លឺ**

**<u>សហព្រះរាជអាជ្ញា:</u>**
ជា លាង
Nicholas KOUMJIAN

**<u>សហមេធាវីការពារក្តីម្ចាស់បណ្តឹងឧទ្ធរណ៍:</u>**
សូ មូស្សេនី
Suzana TOMANOVIC

**<u>មេធាវីដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី:</u>**
ជេត វណ្ណលី
ហុង គឹមសួន
គឹម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន សុវ៉ន
ទី ស្រីនណា
វ៉ែន ពៅ

Laure DESFORGES
Herve DIAKIESE
Ferdinand DJAMMEN-NZEPA
Nicole DUMAS
Isabelle DURAND
François GAUTRY
Martine JACQUIN
Emmanuel JACOMY
Christine MARTINEAU
Barnabe NEKUI
Lyma NGUYEN
Beini YE

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួល "បណ្ដឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងដីកាសម្រេចបដិសេធសំណើរបស់គាត់ស្នើសុំការបំភ្លឺអំពីផ្លូវច្បាប់ក្នុងករណីមានការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេតនៅពេលចេញដីកាដំណោះស្រាយ" ដែលត្រូវបានដាក់ជាភាសាអង់គ្លេសនៅថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១៤ និងជាភាសាខ្មែរនៅថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១៤ ("ម្ចាស់បណ្ដឹងឧទ្ធរណ៍" និង "បណ្ដឹងឧទ្ធរណ៍")[1]។

## I. **សាវតារនីតិវិធី**

1. នៅថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៩ សហព្រះរាជអាជ្ញាអន្តរជាតិស្ដីទីនៅពេលនោះ បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី៣ ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ") ជូនទៅសហចៅក្រមស៊ើបអង្កេត ដោយការដាក់ដីកានេះបានបើក និងចាប់ផ្ដើមបើកកិច្ចស៊ើបសួររបស់តុលាការទៅលើឧក្រិដ្ឋកម្មនានា ដែលម្ចាស់បណ្ដឹងឧទ្ធរណ៍ រួមជាមួយអ្នកដទៃទៀត ត្រូវបានចោទប្រកាន់ថាមានការទទួលខុសត្រូវ[2]។ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមនៅថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១១[3] និងនៅថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤[4]។

2. នៅថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៤ ម្ចាស់បណ្ដឹងឧទ្ធរណ៍បានស្នើឱ្យសហចៅក្រមស៊ើបអង្កេតបង្ហាញការយល់ឃើញរបស់ខ្លួនអំពីផ្លូវច្បាប់ i) ក្នុងករណីមានការខ្វែងយោបល់គ្នារវាងសហចៅស៊ើបអង្កេត ថាតើត្រូវលើកលែងការចោទប្រកាន់ប្រឆាំងនឹងម្ចាស់បណ្ដឹងឧទ្ធរណ៍ ឬត្រូវចោទប្រកាន់បញ្ជូនគាត់ទៅជំនុំជម្រះ និង ii) ក្នុងករណីដែលការខ្វែងយោបល់គ្នា ដែលត្រូវបានបញ្ជូនទៅ

---

[1] ឯកសារ D205/1/1/1។

[2] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ របស់សហព្រះរាជអាជ្ញា ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ឯកសារ D1។ សេចក្ដីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្ដីទីអំពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី៣ ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៩ ឯកសារ D1/1។

[3] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ២០១១ ឯកសារ D65។

[4] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ ឬអំពើហិង្សាយេនឌ័រ ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤ ឯកសារ D191។

អង្គបុរេជំនុំជម្រះ ហើយអង្គបុរេជំនុំជម្រះមិនអាចរកសំឡេងភាគច្រើនបាន ដើម្បីចេញសេចក្តីសម្រេច ដូចដែលមានចែងនៅក្នុងវិធាន ៧២ នៃវិធានផ្ទៃក្នុង ("សំណើ")[5]។

3. នៅថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបដិសេធសំណើដោយកំណត់ថាមិនអាចទទួលយកបាន ដោយផ្អែកទៅលើមូលដ្ឋានថា "មេធាវីជនសង្ស័យកំពុងតែស្នើសុំការបំភ្លឺអំពីច្បាប់ដែលអាចអនុវត្តទៅលើសេណារីយ៉ូមួយ ដែលនៅពេលនេះគឺជាសម្មតិកម្មសុទ្ធសាធ" ("ដីកាសម្រេចដែលរងការជំទាស់")[6]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបញ្ជាក់ថា "ជនសង្ស័យមិនទាន់ត្រូវបានចោទប្រកាន់នៅក្នុងការស៊ើបអង្កេតរបស់តុលាការ" ហើយ "ករណីខ្វែងយោបល់គ្នាដែលដាក់ជាសម្មតិកម្មដោយមេធាវីជនសង្ស័យ មិនទាន់ក្លាយជាការពិតទេ"[7]។

4. ម្ចាស់បណ្តឹងឧទ្ធរណ៍បានដាក់បណ្តឹងឧទ្ធរណ៍ជាភាសាអង់គ្លេស នៅថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១៤ និងជាភាសាខ្មែរនៅថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១៤។ ម្ចាស់បណ្តឹងឧទ្ធរណ៍បានអះអាងថា បណ្តឹង ឧទ្ធរណ៍អាចទទួលយកបាន អនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង។ ជាពិសេស ម្ចាស់បណ្តឹង ឧទ្ធរណ៍បញ្ជាក់ថា មានភស្តុតាងបង្ហាញថា គាត់ទំនងជានឹងត្រូវបានចោទប្រកាន់ ហើយថា សហចៅក្រមស៊ើបអង្កេតអាចមានការខ្វែងយោបល់គ្នាទៅលើថាតើត្រូវចោទប្រកាន់បញ្ជូនគាត់ទៅជំនុំជម្រះ ឬលើកលែងការចោទប្រកាន់ប្រឆាំងនឹងរូបគាត់ នៅពេលចេញដីកាដំណោះស្រាយក្នុងសំណុំរឿង០០៤។ ម្ចាស់បណ្តឹងឧទ្ធរណ៍លើកជំទាស់ថា ច្បាប់នេះពុំមានចែងច្បាស់លាស់ថាតើនឹងមានអ្វីកើតឡើងចំពោះគាត់ ប្រសិនបើមានការខ្វែងយោបល់គ្នាបែបនេះ ដែលបណ្តាលឲ្យមានការរំលោភលើសិទ្ធិជាមូលដ្ឋានរបស់គាត់ក្នុងការទទួលបានសច្ចភាពផ្លូវច្បាប់ និងតម្លាភាព[8]។ នៅក្នុងអង្គសេចក្តី ម្ចាស់បណ្តឹងឧទ្ធរណ៍បានអះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសក្នុងការយល់ឃើញថា សំណើនោះមានលក្ខណៈជាសម្មតិកម្ម និងសម្រេចមិនពិចារណាលើសំណើនោះ ដោយសារមានលទ្ធភាពច្បាស់លាស់ថា ម្ចាស់បណ្តឹងឧទ្ធរណ៍នឹងត្រូវបានចោទប្រកាន់ក្នុង

---

[5] សំណើរបស់ [redacted] សុំឲ្យសហចៅក្រមស៊ើបអង្កេតបង្ហាញការយល់ឃើញអំពីច្បាប់ ក្នុងករណីមានការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេតនៅពេលចេញដីកាដំណោះស្រាយ ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៤ ឯកសារ D205។

[6] ដីកាសម្រេចលើសំណើរបស់ [redacted] សុំការបំភ្លឺទាក់ទងនឹងដីកាដំណោះស្រាយ ប្រសិនបើមានករណីខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ D205/1 កថាខណ្ឌ ៣។

[7] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៣។

[8] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៧។

អង្គបុរេជំនុំជម្រះ E.C.C.C. C.E.T.C. PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

ពេលឆាប់ៗខាងមុខនេះ[9] ហើយថា សហចៅក្រមស៊ើបអង្កេតមានការខ្វែងយោបល់គ្នា នៅពេលចេញដីកាដំណោះស្រាយក្នុងសំណុំរឿង០០៤[10] ដែលម្ចាស់បណ្ដឹងឧទ្ធរណ៍ចាំបាច់ត្រូវទទួលបានការបំភ្លឺទៅលើច្បាប់ជាធរមាន[11]។ ដូច្នេះ ម្ចាស់បណ្ដឹងឧទ្ធរណ៍ស្នើសុំឱ្យអង្គបុរេជំនុំជម្រះបង្គាប់ឱ្យសហចៅក្រមស៊ើបអង្កេតបង្ហាញការយល់ឃើញរបស់ខ្លួន ឬក៏បង្ហាញការយល់ឃើញរបស់ចៅក្រមផ្ទាល់ អំពីច្បាប់ i) ក្នុងករណីមានការខ្វែងយោបល់គ្នារវាងសហចៅស៊ើបអង្កេត ថាតើត្រូវលើកលែងការចោទប្រកាន់ប្រឆាំងនឹងម្ចាស់បណ្ដឹងឧទ្ធរណ៍ ឬត្រូវចោទប្រកាន់បញ្ជូនគាត់ទៅជំនុំជម្រះ និង ii) ក្នុងករណីដែលការខ្វែងយោបល់គ្នានៅចំពោះមុខអង្គបុរេជំនុំជម្រះ ហើយអង្គបុរេជំនុំជម្រះមិនអាចមិនអាចរកសំឡេងភាគច្រើនលើសលប់បាន នៅពេលសម្រេចលើការខ្វែងយោបល់គ្នានេះ[12]។

5. សហព្រះរាជអាជ្ញា និងដើមបណ្ដឹងរដ្ឋប្បវេណី ពុំបានដាក់ចម្លើយតបណាមួយទៅនឹងបណ្ដឹងឧទ្ធរណ៍តាមកាលកំណត់ស្របច្បាប់ឡើយ។

## II. **ភាពអាចទទួលយកបាន**

6. ម្ចាស់បណ្ដឹងឧទ្ធរណ៍ពុំបានលើកឡើងថា បណ្ដឹងឧទ្ធរណ៍អាចទទួលយកបានឡើយ អនុលោមតាមវិធាន ៧៣ ឬ ៧៤ នៃវិធានផ្ទៃក្នុង ដែលចែងអំពីយុត្តាធិការយ៉ាងច្បាស់របស់អង្គបុរេជំនុំជម្រះឡើយ ប៉ុន្តែបានលើកឡើងថា អង្គបុរេជំនុំជម្រះគួរតែប្រកាសថា បណ្ដឹងឧទ្ធរណ៍អាចទទួលយកបាន អនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង។ វិធាននេះចែងនៅក្នុងផ្នែកពាក់ព័ន្ធថា៖

**<u>វិធាន ២១: គោលការណ៍ជាសារវន្ត</u>**

១. ច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ វិធានផ្ទៃក្នុង សេចក្ដីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាលទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និងជនរងគ្រោះ ដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព ដោយគិតដល់លក្ខណៈពិសេសរបស់អង្គជំនុំជម្រះ

[9] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ១៥។

[10] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ១៦-១៧។

[11] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ១៨-២៣។

[12] បណ្ដឹងឧទ្ធរណ៍ សេចក្ដីសន្និដ្ឋាន ទំព័រ ១៥។

វិសាមញ្ញក្នុងតុលាការកម្ពុជា ដូចមានចែងក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ និង កិច្ចព្រមព្រៀង។

7. អង្គបុរេជំនុំជម្រះធ្លាប់បានសម្រេចថា គោលការណ៍ជាសារវ័ន្តដែលមានចែងនៅក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុង ដែលឆ្លុះបញ្ចាំងអំពីលក្ខខណ្ឌតម្រូវនៃការជំនុំជម្រះប្រកបដោយយុត្តិធម៌ដែល អ.វ.ត.ក មានកាតព្វកិច្ចត្រូវអនុវត្ត អនុលោមតាមមាត្រា ១៣(១) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា[13] មាត្រា ៣៥ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក[14] និងមាត្រា ១៤(៣) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ[15] អាចតម្រូវឱ្យអង្គជំនុំជម្រះធ្វើការបកស្រាយក្នុងន័យទូលាយអំពីសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍ ដើម្បីធានាថា កិច្ចដំណើរការនីតិវិធីមានភាពយុត្តិធម៌ និងគោរពគោលការណ៍ចំពោះមុខ ហើយរក្សានូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងអស់[16]។ នៅពេលដែលអង្គហេតុ និងស្ថានភាពពិសេសនៃរឿងក្តីតម្រូវនោះ

---

[13] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៣។

[14] ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ជាមួយនឹងច្បាប់វិសោធនកម្មដែលបានប្រកាសឱ្យប្រើ ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤ ("ច្បាប់ស្តីពី អ.វ.ត.ក")។

[15] *សូមមើល ឧទាហរណ៍* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស ("សំណុំរឿង ០០២") (អបជ៦៤) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចបដិសេធសំណើសុំអនុញ្ញាតថតសំឡេង/រូបភាពវីដេអូនៃការជួបជាមួយលោក អៀង សារី នៅក្នុងមន្ទីរឃុំឃាំង ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១០ ឯកសារ A371/2/12 កថាខណ្ឌ ១៣-១៨, ២៧។

[16] *សូមមើល ឧទាហរណ៍* សំណុំរឿង ០០២ (អបជ១១) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០៩ ឯកសារ A190/I/20 កថាខណ្ឌ ៣៦។ សំណុំរឿង ០០២ (អបជ៧១) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងទៅនឹងសេចក្តីសម្រេចរបស់ ក.ស.ច.ស បដិសេធមិនទទួលយកការដាក់ឯកសារចម្លើយតបរបស់លោក អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៦៦ និងសេចក្តីសង្កេតបន្ថែម និងសំណើសុំផ្អាកដំណើរការនីតិវិធី ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១០ ឯកសារ D390/1/2/4 ("សេចក្តីសម្រេចលើចម្លើយតបរបស់ អៀង សារី") កថាខណ្ឌ ១៣។ សំណុំរឿង ០០២ (អបជ១៤) សេចក្តីសម្រេចលើការជូនដំណឹងរបស់មេធាវីការពារក្តីអំពីកំហុសក្នុងការបកប្រែ ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១០ ឯកសារលេខ ២ ("សេចក្តីសម្រេចលើកំហុសក្នុងការបកប្រែ") កថាខណ្ឌ ៣។ សំណុំរឿង ០០២ (អបជ៧៥) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ ឯកសារ D427/1/30 កថាខណ្ឌ ៤៩។

អង្គបុរេជំនុំជម្រះបានទទួលយកបណ្តឹងឧទ្ធរណ៍ដែលលើកឡើងអំពីបញ្ហាសិទ្ធិជាសារវ័ន្ត ឬ "បញ្ហាយុត្តិធម៌ដ៏ធ្ងន់ធ្ងរ" ដោយអនុវត្តយុត្តិធិការទៅលើបណ្តឹងឧទ្ធរណ៍ដែលមិនស្ថិតនៅក្នុងយុត្តិធិការច្បាស់លាស់របស់ខ្លួន ដោយផ្អែកលើវិធាន ២១ នៃវិធានផ្ទៃក្នុង[17]។ អង្គបុរេជំនុំជម្រះរម្លឹកថា វិធាន ២១ នៃវិធានផ្ទៃក្នុង មិនបានផ្តល់ជាមធ្យោបាយជាស្វ័យប្រវត្តិសម្រាប់បណ្តឹងឧទ្ធរណ៍ ដែលលើកឡើងអំពីទឡ្ហីករណ៍ផ្សេងៗដោយផ្អែកលើសិទ្ធិក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ឡើយ។ ដើម្បីឱ្យអង្គបុរេជំនុំជម្រះអនុវត្តយុត្តាធិការលើបណ្តឹងឧទ្ធរណ៍ អនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង ម្ចាស់បណ្តឹងឧទ្ធរណ៍ត្រូវបង្ហាញថា នៅក្នុងស្ថានភាពពិសេសនៃរឿងក្តីដែលត្រូវដោះស្រាយ ចាំបាច់ត្រូវមានការអន្តរាគមន៍របស់អង្គបុរេជំនុំជម្រះ ដើម្បីការពារមិនឱ្យមានការខូចខាតដែលមិនអាចជួសជុលបានដល់ភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធី ឬសិទ្ធិរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌។

8. អង្គបុរេជំនុំជម្រះយល់ឃើញថា នៅក្នុងករណីនេះ ម្ចាស់បណ្តឹងឧទ្ធរណ៍ពុំបានបង្ហាញថា ការបដិសេធមិនផ្តល់ការបំភ្លឺអំពីច្បាប់នោះតាមរយៈសេចក្តីសម្រេចដែលរងការជំទាស់នេះ ប៉ះពាល់ដល់សិទ្ធិរបស់គាត់ក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ទេ។ អង្គបុរេជំនុំជម្រះយល់ស្របជាមួយនឹងសហចៅក្រមស៊ើបអង្កេតអន្តរជាតិថា សេណារីយ៉ូដែលប្រមើលមើលជាមុននៅក្នុងសំណើនោះ ហើយបានបញ្ជាក់ជាថ្មីម្តងទៀតនៅក្នុងបណ្តឹងឧទ្ធរណ៍ គឺជាសម្មតិកម្មនៅក្នុងដំណាក់កាលនេះ។ ទោះបីជាសេណារីយ៉ូនេះក្លាយជាការពិតក៏ដោយ ក៏មិនមានភាពច្បាស់លាស់ឡើយថាតើម្ចាស់បណ្តឹងឧទ្ធរណ៍នឹងទទួលរងផលប៉ះពាល់ជាក់លាក់អ្វីខ្លះនោះ។ សិទ្ធិក្នុងការទទួលបានសច្ចភាពផ្លូវច្បាប់ និងតម្លាភាពនៃកិច្ចដំណើរការនីតិវិធី ពុំតម្រូវថា ស្ថាប័នតុលាការត្រូវដោះស្រាយបញ្ហាផ្នែកអង្គច្បាប់ មុនពេលបញ្ហាទាំងនោះកើតឡើងពិតប្រាកដចេញពីសាវតារបរិបទ និងអង្គហេតុនៃបញ្ហាទាំងនោះឡើយ។ អង្គបុរេជំនុំជម្រះពុំមានយុត្តាធិការដើម្បីដោះស្រាយបញ្ហាជាសម្មតិកម្ម ឬផ្តល់នូវមតិយោបល់ណែនាំនោះទេ។[18]

---

[17] *សូមមើល ឧទាហរណ៍* សំណុំរឿង ០០២ (អបជ៤២) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់អ្នកស្រី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត បដិសេធសំណើសុំព្យួរកិច្ចស៊ើបសួរ ដោយមូលហេតុរំលោភនីតិវិធី ថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០១០ ឯកសារ D264/2/6 កថាខណ្ឌ ១៣-១៤។ សេចក្តីសម្រេចលើចម្លើយតបរបស់ អៀង សារី កថាខណ្ឌ ១៣ និងសេចក្តីសម្រេចលើកំហុសក្នុងការបកប្រែ កថាខណ្ឌ ២-៦។

[18] សូមមើលឧទាហរណ៍សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ [redacted] ប្រឆាំងនឹងការបដិសេធដោយសន្មត់នូវសំណើទាំងដប់បួន (ទៅសហចៅក្រមស៊ើបអង្កេតអន្តរជាតិ) ចុះថ្ងៃទី ២៣ មេសា ឆ្នាំ ២០១៤ ឯកសារ D៨៧/២/២ កថាខណ្ឌទី២៦ ដែលយោង

9. ដូច្នេះ អង្គបុរេជំនុំជម្រះយល់ឃើញថា បណ្តឹងឧទ្ធរណ៍នេះមិនអាចទទួលយកបានឡើយ។

## III. សេចក្តីសម្រេច

**អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆន្ទ៖**

**បដិសេធ** បណ្តឹងឧទ្ធរណ៍ ដោយចាត់ទុកថាមិនអាចទទួលយកបាន។

អនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សាលដីកានេះបិទផ្លូវប្តឹងតវ៉ា។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០១៤

**ប្រធាន** **អង្គបុរេជំនុំជម្រះ**

**ប្រាក់ គិមសាន** **Rowan DOWNING** **ន័យ ថុល** **Chang-ho CHUNG** **ហួត វុទ្ធី**

---

ទៅសំណុំរឿង ០០២ (អបជ៦០) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតសម្រេចលើសំណើរបស់លោក អៀង សារី ប្រឆាំងនឹងការអនុវត្តទ្រឹស្តីនៃការទទួលខុសត្រូវរបស់ថ្នាក់លើ ចុះថ្ងៃទី ៩ ខែ មិថុនា ឆ្នាំ ២០១០ ឯកសារ D៣៤៥/៥/១១ កថាខណ្ឌទី ១១ "សហចៅក្រមស៊ើបអង្កេតមិនជាប់កាតព្វកិច្ច ដើម្បីផ្តល់សេចក្តីសម្រេចដែលប្រកាសប្រាប់ដូចដែលត្រូវបានស្នើសុំក្នុងពាក្យសុំ ហើយ អង្គបុរេជំនុំជម្រះនឹងមិនផ្តល់មតិយោបល់ណែនាំនោះទេ។